ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៤១ រជ.អប្រក.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរនិងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៧.សរណន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ស្តីពីវិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលាសិលា
- បានឃើញប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹង

ប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងរ៉ែនិងថាមពល

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ..**

ប្រកាសនេះមានគោលបំណងកំណត់នីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព ឬ លិខិតអនុញ្ញាតផ្សេងៗដល់អាជីវករ ឬ ក្រុមហ៊ុនដែលមានបំណងបើកស្ថានីយ ឬ កំពុងដំណើរការស្ថានីយប្រេងឥន្ធនៈ និង/ឬ ឧស្ម័នឥន្ធនៈ ឱ្យបានទាន់ពេលវេលាប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ២ ..**

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចតទៅ៖

**បុគ្គល** សំដៅដល់ រូបវ័ន្តបុគ្គល ឬ នីតិបុគ្គល។

**ប្រេងឥន្ធនៈ** សំដៅដល់ល្បាយអ៊ីដ្រូកាបួរដែលនៅក្នុងលក្ខខណ្ឌបរិយាកាសធម្មតាជាវត្ថុធាតុរាវ ហើយដែលអាចប្រើសម្រាប់អុចបំភ្លឺ ឬ បញ្ឆេះម៉ាស៊ីន ដើម្បីផ្តល់ថាមពលឱ្យយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទអាចដំណើរការបាន មានប្រេងសាំង ប្រេងម៉ាស៊ូត ប្រេងកាតដុតបំភ្លឺ ប្រេងយន្តហោះ និងប្រេងខ្មៅជាដើម។

**ឧស្ម័នឥន្ធនៈ** សំដៅដល់ល្បាយអ៊ីដ្រូកាបួរដែលនៅក្នុងលក្ខខណ្ឌបរិយាកាសធម្មតាជាឧស្ម័ន ហើយដែលអាចប្រើសម្រាប់ដុត ឬបញ្ឆេះម៉ាស៊ីនដើម្បីផ្តល់ថាមពលឱ្យយានយន្តនិងគ្រឿងយន្តគ្រប់ប្រភេទអាចដំណើរការបាន មានដូចជាឧស្ម័នអិលភីជី ឧស្ម័នអិលអិនជី និងឧស្ម័នស៊ីអិនជី ជាដើម។

**វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ** សំដៅដល់លិខិតផ្លូវការចេញដោយក្រសួងរ៉ែនិងថាមពល ដែលបញ្ជាក់ថាការរៀបចំស្ថានីយមួយមានលក្ខណៈបច្ចេកទេសសុវត្ថិភាព អនុលោមតាម សារាចរស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល។

**លិខិតអនុញ្ញាតដំណើរការស្ថានីយ** សំដៅដល់លិខិតផ្លូវការចេញដោយក្រសួងរ៉ែនិងថាមពល អនុញ្ញាតឱ្យបុគ្គលណាមួយដំណើរការនូវស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និង/ឬស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈដែលបានសាងសង់រួច ។

**ស្ថានីយប្រេងឥន្ធនៈ** សំដៅដល់ទីតាំងអាជីវកម្មប្រេងឥន្ធនៈដែលមានលទ្ធភាពស្តុកប្រេងឥន្ធនៈ ចន្លោះពី ២០១ (ពីររយមួយ) លីត្រ ដល់ ១៥០ ០០០ (មួយរយហាសិបពាន់) លីត្រ សម្រាប់លក់ចែកចាយដល់សាធារណៈជន។

**ស្ថានីយឧស្ម័នឥន្ធនៈ** សំដៅដល់ទីតាំងអាជីវកម្មឧស្ម័នឥន្ធនៈដែលមានលទ្ធភាពផ្ទុកឧស្ម័នឥន្ធនៈ មិនលើសពី ១០០ ០០០ (មួយរយពាន់) លីត្រ ហើយសម្រាប់តែចាក់បញ្ចូលយានយន្តដល់សាធារណៈជន។

## ជំពូកទី ២
## ការដាក់ពាក្យស្នើសុំ

**ប្រការ៣ ..**

បុគ្គលដែលអាចបង្កើតស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈបាន ត្រូវមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយពីក្រសួងរ៉ែនិងថាមពល។

បុគ្គលដែលអាចដំណើរការស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈបាន ត្រូវមានលិខិតអនុញ្ញាតដំណើការស្ថានីយពីក្រសួងរ៉ែនិងថាមពល។

**ប្រការ៤ ..**

បុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ ឬលិខិតអនុញ្ញាតដំណើរការស្ថានីយស្របតាមប្រការ៣នៃប្រកាសនេះ អាចទទួលបានពាក្យស្នើសុំ ឬព័ត៌មានបន្ថែម តាមរយៈលេខាធិការដ្ឋានច្រកចេញចូលតែមួយនៃក្រសួងរ៉ែនិងថាមពល មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ឬគេហទំព័រអគ្គនាយកដ្ឋានប្រេងកាតដែលមានអាសយដ្ឋាន www.mme.gov.kh/gdp.php។

**ប្រការ៥ ..**

អ្នកស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ ត្រូវបំពេញពាក្យស្នើសុំមួយច្បាប់តាមទម្រង់លេខ**០០១វបស** ដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ៦ ..**

អ្នកស្នើសុំលិខិតអនុញ្ញាតដំណើរការស្ថានីយ ត្រូវបំពេញពាក្យស្នើសុំមួយច្បាប់តាមទម្រង់លេខ **០០១លអដ** ដូចមានក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៧ ..**

ពាក្យស្នើសុំទាំងអស់ត្រូវដាក់នៅមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត នៅរៀងរាល់ថ្ងៃធ្វើការនិងម៉ោងធ្វើការ ហើយមន្ទីររ៉ែនិងថាមពលរាជធានី ខេត្តត្រូវបញ្ជូនសំណុំឯកសារស្នើសុំទាំងនេះឱ្យដល់ច្រកចេញចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំនោះ។

មន្ត្រីដែលទទួលពាក្យស្នើសុំនៅច្រកចេញចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ភាពពេញលេញនៃពាក្យស្នើសុំនីមួយៗ រួមទាំងសំណុំឯកសារពាក់ព័ន្ធដែលភ្ជាប់មកជាមួយ។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមានភាពពេញលេញ ត្រូវចេញសលាកបត្រទទួលពាក្យជូនអ្នកដាក់ពាក្យស្នើសុំតាមទម្រង់ បង្កាន់ដៃទទួល **បទ០០១**។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមិនទាន់ពេញលេញ មន្ត្រីទទួលពាក្យត្រូវបដិសេធពាក្យស្នើសុំ ហើយណែនាំឱ្យអ្នកដាក់ពាក្យបំពេញបន្ថែមតាមបញ្ជីផ្ទៀងផ្ទាត់ដូចខាងក្រោម៖

១- សម្រាប់ការស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ ទម្រង់ **លបប០០១**

២- សម្រាប់ការស្នើសុំលិខិតអនុញ្ញាតដំណើរការស្ថានីយ ទម្រង់ **លបដ០០១**

៣- សម្រាប់ការស្នើសុំកែសម្រួលស្ថានីយ ទម្រង់ **លបក០០១**

៤- សម្រាប់ការស្នើសុំប្តូរម្ចាស់ស្ថានីយ ទម្រង់ **លបម០០១**។

## ជំពូកទី ៣
## ការពិនិត្យនិងសម្រេចលើពាក្យស្នើសុំ

**ប្រការ៨ ._**

អគ្គនាយកដ្ឋានប្រេងកាតមានភារកិច្ចពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសារស្នើសុំ។ នីតិវិធីនៃការពិនិត្យនិងផ្តល់យោបល់នេះមានដូចតទៅ៖

ក- ពិនិត្យរាល់ឯកសារតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានបច្ចេកទេសសុវត្ថិភាព ដូចមានចែងក្នុងសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ។

ខ- ក្រុមមន្ត្រីជំនាញត្រូវចុះពិនិត្យទីតាំងស្នើសុំជាក់ស្តែងតាមការចាំបាច់ ដើម្បីធ្វើកំណត់ហេតុចុះត្រួតពិនិត្យ។

គ- រៀបចំរបាយការណ៍និងកំណត់បង្ហាញជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលពិនិត្យនិងសម្រេច។

**ប្រការ៩ ._**

អគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល មានរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការដើម្បីពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសារស្នើសុំ។

**ប្រការ១០ ._**

បន្ទាប់ពីទទួលបានមតិយោបល់ពីអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល ថ្នាក់ដឹកនាំនិងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលមានរយៈពេល ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការដើម្បីសម្រេច ៖

- ឯកភាពតាមសំណើ
- ឯកភាពតាមសំណើដោយមានលក្ខខណ្ឌ
- ស្នើឱ្យបំភ្លឺបន្ថែម ឬ តម្រូវឱ្យបុគ្គលស្នើសុំធ្វើការកែសម្រួលបំពេញបន្ថែម ឬ
- ធ្វើការបដិសេធចំពោះពាក្យស្នើសុំដោយមានមូលហេតុនៃការសម្រេចជាលាយលក្ខណ៍អក្សរ។

## ជំពូកទី ៤
## សុពលភាពនៃលិខិតអនុញ្ញាតដំណើរការ

**ប្រការ១១ ._**

លិខិតអនុញ្ញាតដំណើរការស្ថានីយមានសុពលភាព ០២ (ពីរ) ឆ្នាំ។ ម្ចាស់ស្ថានីយត្រូវមកដាក់ពាក្យស្នើសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃ មុនពេលផុតកំណត់សុពលភាពនៅមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ហើយមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារស្នើសុំទាំងនេះឱ្យដល់ច្រកចេញ ចូលតែមួយនៃក្រសួងរ៉ែនិងថាមពលក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំនោះ។

**ប្រការ១២ ._**

អ្នកស្នើសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ត្រូវបំពេញពាក្យស្នើសុំមួយច្បាប់តាមទម្រង់លេខ ០០១**លអបជ** ដូចមានក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

នីតិវិធីនៃការដាក់ពាក្យ ការពិនិត្យ និងការសម្រេចត្រូវអនុវត្តដូចប្រការ៧ ប្រការ៨ ប្រការ៩ និងប្រការ១០ នៃប្រកាសនេះ។

## ជំពូកទី ៥
## ការកែសម្រួលនិងការប្តូរម្ចាស់ស្ថានីយ

**ប្រការ១៣ ._**

ក្នុងរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ម្ចាស់ស្ថានីយអាចកែសម្រួលឬផ្ទេរស្ថានីយទៅឱ្យម្ចាស់ផ្សេងបាន ប៉ុន្តែម្ចាស់ស្ថានីយត្រូវទទួលការឯកភាពពីក្រសួងរ៉ែនិងថាមពលជាមុន។ ការកែសម្រួលស្ថានីយដែលតម្រូវឱ្យមានការឯកភាពពីក្រសួងរ៉ែនិងថាមពល សំដៅដល់ការកែឈ្មោះស្ថានីយ បន្ថែមអគារ កែឬបន្ថែមពោងប្រេងឬឧស្ម័នឥន្ធនៈ កែទីតាំងឬបន្ថែមទូចាក់ប្រេងឬឧស្ម័នឥន្ធនៈ កែទីតាំងកបំពង់ទទួលប្រេងឬឧស្ម័នឥន្ធនៈ កែទីតាំងបំពង់ខ្យល់ កែទីតាំងបំពង់បង្ហូរប្រេងឬឧស្ម័នឥន្ធនៈ កែសំណង់អាងញែកសំណល់រឹង ប្រេងនិងទឹក ដែលការកែ ឬបន្ថែមទាំងនេះខុសពីគំនូសប្លង់បច្ចេកទេសរៀបចំស្ថានីយដែលបានទទួលស្គាល់ពីក្រសួងរ៉ែនិងថាមពល។ រាល់ការផ្លាស់ប្តូរផ្សេងៗទៀតម្ចាស់ស្ថានីយត្រូវជូនដំណឹងមកក្រសួងរ៉ែនិងថាមពលជាមុន។

**ប្រការ១៤ ._**

អ្នកស្នើសុំកែសម្រួលស្ថានីយប្រេងឥន្ធនៈ ឬស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ ត្រូវបំពេញពាក្យស្នើសុំមួយច្បាប់តាមទម្រង់លេខ ០០១លកស ដូចមានក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

**ប្រការ១៥ ..**

ការស្នើសុំផ្លាស់ប្តូរម្ចាស់ស្ថានីយប្រេងឥន្ធនៈ ឬស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់លេខ **០០១លបម** ដូចមានក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

នីតិវិធីនៃការដាក់ពាក្យ ការពិនិត្យ និងការសម្រេចត្រូវអនុវត្តដូចប្រការ៧ ប្រការ៨ ប្រការ៩ និងប្រការ១០ នៃប្រកាសនេះ។

## ជំពូកទី ៦
## ការបង់កម្រៃសេវាកម្ម

**ប្រការ១៦ ..**

ម្ចាស់ស្ថានីយប្រេងឥន្ធនៈ ម្ចាស់ស្ថានីយឧស្ម័នឥន្ធនៈ ឬម្ចាស់ស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ ដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយ លិខិតអនុញ្ញាតដំណើរការស្ថានីយ បន្តសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ កែសម្រួលស្ថានីយ ឬប្តូរម្ចាស់ស្ថានីយត្រូវបង់កម្រៃសេវាសាធារណៈដូចបានកំណត់នៅក្នុងប្រកាសខាងក្រោម៖

- ប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង
- ប្រកាសរួមលេខ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**ប្រការ១៧ ..**

ស្ថានីយប្រេងឥន្ធនៈដែលកំពុងដំណើរការ ម្ចាស់ស្ថានីយត្រូវកែសម្រួលស្ថានីយប្រេងឥន្ធនៈរបស់ខ្លួន តាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈឱ្យចប់ជាស្ថាពរមុនថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈដែលកំពុងដំណើរការ ម្ចាស់ស្ថានីយត្រូវកែសម្រួលស្ថានីយរបស់ខ្លួន តាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី ១៦ ខែ ឧសភា

ឆ្នាំ២០១៨ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈឱ្យចប់ជាស្ថាពរមុនថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ១៨ ..**

ត្រូវទុកជានិរាករណ៍នូវប្រកាសដូចខាងក្រោម៖

- ប្រកាសលេខ០០៩២ រថ.បវប.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- ប្រកាសលេខ១០៥ រថ.បវប.ប្រក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយឧស្ម័នឥន្ធនៈ និង ស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល និង
- ប្រកាសលេខ១០៦ រថ.បវប.ប្រក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ ៨ ប្រការ១១ ប្រការ១២ ប្រការ១៥ និងប្រការ១៧ នៃប្រកាសលេខ០០៩២ រថ.បវប.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល។

**ប្រការ១៩ ..**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ២កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៨
**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ១៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ១ នៃប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភាឆ្នាំ ២០១៨**
**ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ**
**ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ**

ទម្រង់លេខ ០០១វបស

## ពាក្យសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ
APPLICATION FORM FOR CERTIFICATE OF FILLING STATION TECHNICAL SAFETY

រូបថតអ្នកស្នើសុំ
Photo of applicant
4 x 6

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន។
The following information is to be filed by the owner of the filling station or president of the company.

---

**១- អំពីអ្នកស្នើសុំ (Applicant Information)***

☐ រូបវន្តបុគ្គល (Natural Person) ☐ នីតិបុគ្គល (Legal Entity)

ឈ្មោះអ្នកស្នើសុំ៖ ____________ សញ្ជាតិ៖ ____________ ភេទ៖ ☐ ប្រុស (Male)
Applicant's Name: ____________ Nationality: ____________ Sex: ☐ ស្រី (Female)

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number): ____________ ថ្ងៃខែឆ្នាំកំណើត (DoB): ____________

អាសយដ្ឋានអ្នកស្នើសុំ (Address of Applicant): ____________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____________ អ៊ីម៉ែល (E-mail): ____________

បំពេញព័ត៌មានខាងក្រោម ប្រសិនបើម្ចាស់អាជីវកម្មជានីតិបុគ្គល (Complete the Following If the Applicant is a Legal Entity)៖

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ ប្រធានក្រុមហ៊ុន (Chairman/Managing Director/Director)
Position of Applicant in Company/Firm : ☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative)
(សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney)

នាមករណ៍ក្រុមហ៊ុន ៖ ____________ លេខចុះបញ្ជីពាណិជ្ជកម្ម : ____________
Firm/Company's Name : ____________ (Business Registration No)

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ (Office's Address) : ____________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____________ អ៊ីម៉ែល (E-mail) : ____________

(*) ករណីអ្នកស្នើសុំជារូបវន្តបុគ្គល អ្នកស្នើសុំនឹងក្លាយទៅជាម្ចាស់ស្ថានីយស្របច្បាប់ ក្រោយពេលទទួលបានការអនុញ្ញាតដំណើរការស្ថានីយ។ ករណីអ្នកស្នើសុំជានីតិបុគ្គល ក្រុមហ៊ុននឹងក្លាយទៅជាម្ចាស់ស្ថានីយស្របច្បាប់ ក្រោយពេលទទួលបានការអនុញ្ញាតដំណើរការស្ថានីយ។ (In case of the applicant is natural person, the applicant will be legally the ownership of the filling station after getting the operation permission. In case of the applicant is a legal entity, the company/firm will be legally the ownership of the filling station after getting the operation permission)

**២- អំពីគម្រោងស្ថានីយ (Filling Station)**

**២.១- ប្រភេទស្ថានីយ (Type of Filling Station)**

☐ ស្ថានីយប្រេងឥន្ធនៈ (Fuel Station)
☐ ស្ថានីយឧស្ម័នឥន្ធនៈ (Gas Station)
☐ ស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ (Joint Fuel and Gas Station)

**២.២- ព័ត៌មានអំពីទីតាំងស្ថានីយ (Information of Filling Station Location)**

ឈ្មោះ ឬ ស្លាកយីហោស្ថានីយ ( Name of Filling Station ): ____________

អាសយដ្ឋានស្ថានីយ (Address of Filling Station): ____________

ទំហំផ្ទៃដីសរុប - ម៉ែត្រក្រឡា ( Area, $m^2$ ) : ____________ ប្រវែងក្បាលដី (Width) ____ ប្រវែងជម្រៅដី(Length) ____________

និយាមការ (Coordination): រយៈបណ្តោយ (Longitude): ____________ រយៈទទឹង (Latitude): ____________

២.៣- ព័ត៌មានពីសម្ភារៈ និងឋបនភណ្ឌបច្ចេកទេសស្ថានីយ (Information of the Equipment and Facilities)

២.៣.១. ពោង (Storage Tanks)

ចំនួនពោងសរុប (Number of Storage Tanks) ____________________

ពោងទី១ (1st Tank) ៖ ប្រភេទផលិតផល (Type of Product) __________ ប្រភេទពោង (Type of Tank): __________

ចំណុះ (Volume) __________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី២ (2nd Tank) ៖ ប្រភេទផលិតផល (Type of Product) __________ ប្រភេទពោង (Type of Tank): __________

ចំណុះ (Volume) __________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី៣ (3rd Tank) ៖ ប្រភេទផលិតផល (Type of Product) __________ ប្រភេទពោង (Type of Tank): __________

ចំណុះ (Volume) __________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី៤ (4th Tank) ៖ ប្រភេទផលិតផល (Type of Product) __________ ប្រភេទពោង (Type of Tank): __________

ចំណុះ (Volume) __________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី៥ (5th Tank) ៖ ប្រភេទផលិតផល (Type of Product) __________ ប្រភេទពោង (Type of Tank): __________

ចំណុះ (Volume) __________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី៦ (6th Tank) ៖ ប្រភេទផលិតផល (Type of Product) __________ ប្រភេទពោង (Type of Tank): __________

ចំណុះ (Volume) __________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី... (...Tank) ៖ ប្រភេទផលិតផល (Type of Product) __________ ប្រភេទពោង (Type of Tank): __________

ចំណុះ (Volume) __________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី... (...Tank) ៖ ប្រភេទផលិតផល (Type of Product) __________ ប្រភេទពោង (Type of Tank): __________

ចំណុះ (Volume) __________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី... (...Tank) ៖ ប្រភេទផលិតផល (Type of Product) __________ ប្រភេទពោង (Type of Tank): __________

ចំណុះ (Volume) __________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

(សូមភ្ជាប់មកជាមួយនូវយថាប្រភេទនៃពោងនីមួយៗ គំនូសប្លង់អាងពោង និងប្លង់ដំឡើងពោង) (Please Attach the Specification of Each Tank, Chamber Design, and Installation Drawing of Tanks)

២.៣.២. ទូចាក់ (Dispenser)

ចំនួនទូចាក់ (Number of Dispensers) __________ ចំនួនចំពួយចាក់សរុប (Number of Nozzles) __________

(សូមភ្ជាប់មកជាមួយនូវយថាប្រភេទនៃទូចាក់នីមួយៗ និងគំនូសបំព្រួញប្លង់ដំឡើងទូចាក់)

(Please Attach the Specification of Each Dispenser and Installation Drawing of Dispensers)

២.៣.៣. ប្រព័ន្ធបំពង់ខ្យល់ (Venting System)

ចំនួនបំពង់ខ្យល់ (Number of Vents) __________ ទំហំបំពង់ខ្យល់(Size) __________ ប្រវែងបំពង់ខ្យល់ (Length) __________

(សូមភ្ជាប់មកជាមួយនូវគំនូសបំព្រួញប្រព័ន្ធបំពង់ខ្យល់) (Please Attach the Layout of the Venting System)

២.៣.៤ ប្រព័ន្ធបំពង់បង្ហូរ ( Piping System)

សូមភ្ជាប់មកជាមួយនូវគំនូសបំព្រួញប្រព័ន្ធបំពង់បង្ហូរ (Please Attach the Layout of the Piping System)

២.៣.៥ អំពីអគារផ្សេងៗ នៅក្នុងស្ថានីយ ( Buildings Within Filling Station)

☐ អគារការិយាល័យ(Office Building) ☐ អគារសេវាកម្ម (Service Buildings) ☐ ហាងទំនិញ (Store)

☐បន្ទប់បុគ្គលិក (Employee Room) ☐ អគារផ្សេងៗ (Other Buildings) __________

២.៣.៦ អំពីអគារផ្សេងៗ នៅជុំវិញស្ថានីយ ( Buildings Surrounding of Filling Station)

☐ អគារការិយាល័យ(Office Building) ☐ អគារសេវាកម្ម (Service Buildings) ☐ ហាងទំនិញ (Store) ☐ ភោជនីយដ្ឋាន (Restaurant)

☐ លំនៅដ្ឋាន (Residences) ☐អគារផ្សេងៗ (Other Buildings) __________

២.៣.៧ អំពីឧបករណ៍ពន្លត់អគ្គិភ័យ និងវត្ថុជក់ប្រេង (Firefighting Equipment and Absorbent Materials)

សូមភ្ជាប់មកជាមួយនូវគំនូសបំព្រួញបង្ហាញទីតាំងឧបករណ៍ពន្លត់អគ្គិភ័យ និងវត្ថុជក់ប្រេង (Please Attach the Layout of the Firefighting Equipment and Absorbent Materials)

**២.៣.៨ អំពីប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក** (Oil-Water Separation System)

ចង្អូរប្រមូលទឹកចោល (Collection Chanel): បណ្តោយ (Length) ______ ប្រវែងទទឹង (Width) ______ ជម្រៅ (Depth) ______

អាងញែក (Oil-water Separation Chamber: បណ្តោយ (Length) ______ ប្រវែងទទឹង (Width) ______ ជម្រៅ (Depth) ______

(សូមភ្ជាប់មកជាមួយនូវគំនូសបំព្រួញប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក: Please attach the layout of Oil-Water Separation System)

**២.៣.៩ អំពីការសាងសង់**

កាលបរិច្ឆេទនៃការគ្រោងចាប់ផ្តើមសាងសង់ (Planning Date of Construction Commencement ______

កាលបរិច្ឆេទនៃការគ្រោងសាងសង់ចប់ជាស្ថាពរ (Planning Date of Completed Construction): ______

កាលបរិច្ឆេទនៃការគ្រោងដាក់ដំណើរការ (Planning Date of Operating): ______

**៣- ឯកសារភ្ជាប់មកជាមួយ** (Supporting Documents Attached) :

☐ រូបថតម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន ៤x៦ ចំនួន ៣សន្លឹក (3 Photos of Filling Station Owner or Company President 4x6)

☐ ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (Copy of ID or Passport) ចំនួន ១ ច្បាប់ (1 copy)

☐ ផែនទីបង្ហាញទីតាំងស្ថានីយដែលត្រូវបង្កើត (Location Map of Filling Station) ចំនួន ១ ច្បាប់ (1 copy)

☐ គំនូសប្លង់បច្ចេកទេសរៀបចំសុវត្ថិភាពស្ថានីយ ចំនួន ១ ច្បាប់ (1 copy)
(Technical Drawing of Safety Preparation of Filling Station)

☐ បង្កាន់ដៃកម្រៃសេវាសាធារណៈពិនិត្យពាក្យស្នើសុំ ចំនួន ១ ច្បាប់ (1 copy)
(Receipt of Public Service Fee for the Application)

☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីជានីតិបុគ្គល) ចំនួន ១ ច្បាប់ (1 copy)
(Copy of Statute and Certificate of Business Registration, If Legal Entity)

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ដូចមានយោងខាងលើ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។ I/We, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃ.................. ខែ.................. ឆ្នាំ.......... ព.ស......................

.......................... ថ្ងៃទី.......... ខែ.............. ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
(Signature and Name of Applicant)

សម្រាប់មន្ត្រីទទួលពាក្យ៖..........................................
(Official Use Only)

**ឧបសម្ព័ន្ធទី ២ នៃប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភាឆ្នាំ ២០១៨**
**ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ**
**ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ**

ទម្រង់លេខ ០០១ឈអជ

# ពាក្យសុំលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈ

## APPLICATION FORM FOR FILLING STATION OPERATION PERMIT

រូបថតអ្នកស្នើសុំ
Photo of applicant
4 x 6

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន។
The following information is to be filed by the owner of the filling station or president of the company.

- ចំពោះអ្នកដែលមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សូមបំពេញព័ត៌មានផ្នែកទី១។
- ចំពោះអ្នកមិនដែលមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សូមបំពេញព័ត៌មានផ្នែកទី២។

**ផ្នែកទី១**

**១- ស្ថានភាពទូទៅ**

- ☐ ស្ថានីយប្រេងឥន្ធនៈ (Fuel Station)
- ☐ ស្ថានីយឧស្ម័នឥន្ធនៈ (Gas Station)
- ☐ ស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ (Joint Fuel and Gas Station)

វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយ (Certificate of Filling Station Technical Safety) លេខ៖ ____________

កាលបរិច្ឆេទនៃការបញ្ចប់ការសាងសង់ (Planning Date of Completion) ____________

កាលបរិច្ឆេទនៃការគ្រោងដាក់ដំណើរការ (Planning Date of Operating) ____________

**២- ព័ត៌មានអំពីបុគ្គលិកស្ថានីយ** (Information of Filling Station Employees)

ឈ្មោះអ្នកគ្រប់គ្រង ( Name of Manager): ____________ ភេទ (Sex) ______ ថ្ងៃខែឆ្នាំកំណើត (DoB) ____________

សញ្ជាតិ (Nationality): ____________ លេខទូរស័ព្ទ(Tel.) ____________

(សូមភ្ជាប់មកនូវប្រវត្តិរូបសង្ខេប របស់អ្នកគ្រប់គ្រង Please Attach the Curriculum Vitae)

ចំនួនបុគ្គលិកសរុប( Total Number of Employees): ____________ នាក់

**៣- ព័ត៌មានពីទុនវិនិយោគ** (Information of the Investment)

តម្លៃប៉ាន់ស្មានវិនិយោគសរុប-គិតជារៀល (Estimated Total Investment Cost in Riel): ____________

**៤- ឯកសារភ្ជាប់មកជាមួយ** (Supporting Documents Attached) :

- ☐ រូបថតម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន ៤x៦ ចំនួន ៣សន្លឹក (3 Photos of Filling Station Owner or Company President 4x6)
- ☐ ច្បាប់ចម្លងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ (Certificate of Filling Station Technical Safety) — ចំនួន ១ ច្បាប់ (1 copy)
- ☐ ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ពីស្ថាប័នមានសមត្ថកិច្ច (Copy of Construction Permits from Authorities) — ចំនួន ១ ច្បាប់ (1 copy)
- ☐ បង្កាន់ដៃតម្រៃសេវាសាធារណៈពិនិត្យពាក្យស្នើសុំ (Receipt of Public Service Fee for the Application — ចំនួន ១ ច្បាប់ (1 copy)

9

## ផ្នែកទី២

**១- អំពីអ្នកស្នើសុំ (Applicant Information)***

☐ រូបវន្តបុគ្គល (Natural Person) ☐នីតិបុគ្គល (Legal Entity)

ឈ្មោះអ្នកស្នើសុំ៖ ____________ សញ្ជាតិ៖ ____________ ភេទ៖ ☐ ប្រុស (Male)

Applicant's Name: ____________ Nationality: ____________ Sex: ☐ ស្រី (Female)

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number): ____________ ថ្ងៃខែឆ្នាំកំណើត (DoB): ____________

អាសយដ្ឋានអ្នកស្នើសុំ (Address of Applicant): ____________

____________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____________ អ៊ីមែល (E-mail): ____________

បំពេញព័ត៌មានខាងក្រោម ប្រសិនបើម្ចាស់អាជីវកម្មជានីតិបុគ្គល (Complete the following if the applicant is a legal entity) ៖

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ ប្រធានក្រុមហ៊ុន (Chairman/Managing Director/Director)

Position of Applicant in Company/Firm : ☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative)

(សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney)

នាមករណ៍ក្រុមហ៊ុន ៖ ____________ លេខចុះបញ្ជីពាណិជ្ជកម្ម : ____________

Firm/Company's Name : ____________ Business Registration No ____________

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ (Office's Address) : ____________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____________ អ៊ីមែល (E-mail) : ____________

(*) ករណីអ្នកស្នើសុំជារូបវន្តបុគ្គល អ្នកស្នើសុំនឹងក្លាយទៅជាម្ចាស់ស្ថានីយស្របច្បាប់ ក្រោយពេលទទួលបានវិញ្ញាបនបត្រនេះ។ ករណីអ្នកស្នើសុំជានីតិបុគ្គល ក្រុមហ៊ុននឹងក្លាយទៅជាម្ចាស់ស្ថានីយស្របច្បាប់ ក្រោយពេលទទួលបានវិញ្ញាបនបត្រនេះ។ (In case of the applicant is natural person, the applicant will be legally the ownership of the filling station after getting this certificate. In case of the applicant is a legal entity, the company/firm will be legally the ownership of the filling station after getting this certificate)

**២- អំពីគម្រោងស្ថានីយ (Filling Station)**

**២.១- ប្រភេទស្ថានីយ (Type of Filling Station)**

- ☐ ស្ថានីយប្រេងឥន្ធនៈ (Fuel Station)
- ☐ ស្ថានីយឧស្ម័នឥន្ធនៈ (Gas Station)
- ☐ ស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ (Joint Fuel and Gas Station)

**២.២- ព័ត៌មានអំពីទីតាំងស្ថានីយ (Information of Filling Station Location)**

ឈ្មោះ ឬ ស្លាកយីហោស្ថានីយ ( Name of Filling Station ): ____________

អាសយដ្ឋានស្ថានីយ (Address of Filling Station ): ____________

____________

____________

ទំហំផ្ទៃដីសរុប - ម៉ែត្រក្រឡា ( Area, $m^2$ ) : ____________ ប្រវែងក្បាលដី (Width) ____________ ប្រវែងជម្រៅដី(Length) ____________

និយាមការ (Coordination): រយៈបណ្តោយ (Longitude): ____________ រយៈទទឹង (Latitude): ____________

**២.៣- ព័ត៌មានពីសម្ភារៈ និងបរិក្ខារបច្ចេកទេសស្ថានីយ (Information on the Equipment and Facilities)**

**២.៣.១. ពោង (Storage Tanks)**

ចំនួនពោងសរុប (Number of Storage Tanks) ____________

ពោងទី១ (1st Tank) ៖ ប្រភេទផលិតផល (Type of Product) ____________ ប្រភេទពោង (Type of Tank ): ____________

ចំណុះ (Volume) ____________ លីត្រ (Littre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី២ (2nd Tank) ៖ ប្រភេទផលិតផល (Type of Product) ____________ ប្រភេទពោង (Type of Tank ): ____________

៦

Raet

ចំណុះ (Volume)________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី៣ (3rd Tank) ៖ ប្រភេទផលិតផល (Type of Product)________ ប្រភេទពោង (Type of Tank ):________

ចំណុះ (Volume)________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី៤ (4th Tank) ៖ ប្រភេទផលិតផល (Type of Product)________ ប្រភេទពោង (Type of Tank ):________

ចំណុះ (Volume)________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី៥ (5th Tank) ៖ ប្រភេទផលិតផល (Type of Product)________ ប្រភេទពោង (Type of Tank ):________

ចំណុះ (Volume)________ លីត្រ (Litre) ☐ កប់ដី ☐ ដាក់លើដី

ពោងទី៦ (6th Tank) ៖ ប្រភេទផលិតផល (Type of Product)________ ប្រភេទពោង (Type of Tank ):________

ចំណុះ (Volume)________ លីត្រ (Litre) កប់ដី ដាក់លើដី

ពោងទី... (...Tank) ៖ ប្រភេទផលិតផល (Type of Product)________ ប្រភេទពោង (Type of Tank ):________

ចំណុះ (Volume)________ លីត្រ (Litre) កប់ដី ដាក់លើដី

ពោងទី... (...Tank) ៖ ប្រភេទផលិតផល (Type of Product)________ ប្រភេទពោង (Type of Tank ):________

ចំណុះ (Volume)________ លីត្រ (Litre) កប់ដី ដាក់លើដី

ពោងទី... (...Tank) ៖ ប្រភេទផលិតផល (Type of Product)________ ប្រភេទពោង (Type of Tank ):________

ចំណុះ (Volume)________ លីត្រ (Litre) កប់ដី ដាក់លើដី

(សូមភ្ជាប់មកជាមួយនូវយថាប្រភេទនៃពោងនីមួយៗ គំនូសប្លង់រោងពោង និងប្លង់ដំឡើងពោង) (Please Attach the Specification of Each Tank, Chamber Design, and Installation Drawing of Tanks)

**២.៣.២. ទូចាក់** (Dispenser)

ចំនួនទូចាក់ (Number of Dispensers)________ ចំនួនចំពួយចាក់សរុប (Total Number of Nozzles)________

(សូមភ្ជាប់មកជាមួយនូវយថាប្រភេទនៃទូចាក់នីមួយៗ និងគំនូសបំព្រួញប្លង់ដំឡើងទូចាក់)

(Please Attach the Specification of Each Dispenser and Installation Drawing of Dispensers)

**២.៣.៣. ប្រព័ន្ធបំពង់ខ្យល់** (Venting System)

ចំនួនបំពង់ខ្យល់ (Number of Vents)________ ទំហំបំពង់ខ្យល់(Size)________ ប្រវែងបំពង់(Length)________

(សូមភ្ជាប់មកជាមួយនូវគំនូសបំព្រួញប្រព័ន្ធបំពង់ខ្យល់) (Please Attach the Layout of the Venting System)

**២.៣.៤ ប្រព័ន្ធបំពង់បង្ហូរ** ( Piping System)

សូមភ្ជាប់មកជាមួយនូវគំនូសបំព្រួញប្រព័ន្ធបំពង់បង្ហូរ (Please Attach the Layout of the Piping System)

**២.៣.៥ អំពីអគារផ្សេងៗ នៅក្នុងស្ថានីយ** ( Buildings Within Filling Station)

☐ អគារការិយាល័យ(Office Building) ☐ អគារសេវាកម្ម (Service Buildings) ☐ ហាងទំនិញ (Store)

☐ បន្ទប់បុគ្គលិក (Employee Room) ☐ អគារផ្សេងៗ (Other Buildings)________

**២.៣.៦ អំពីអគារផ្សេងៗ នៅជុំវិញក្រៅស្ថានីយ** ( Buildings Surrounding of Filling Station)

☐ អគារការិយាល័យ(Office Building) ☐ អគារសេវាកម្ម (Service Buildings) ☐ ហាងទំនិញ (Store) ☐ អាហារដ្ឋាន (Restaurant)

☐ លំនៅដ្ឋាន (Residences) ☐អគារផ្សេងៗ (Other Buildings)________

**២.៣.៧ អំពីឧបករណ៍ពន្លត់អគ្គិភ័យ និងវត្ថុជក់ប្រេង** (Firefighting Equipment and Absorbent Materials)

សូមភ្ជាប់មកជាមួយនូវគំនូសបំព្រួញបង្ហាញទីតាំងឧបករណ៍ពន្លត់អគ្គិភ័យ និងវត្ថុជក់ប្រេង (Please Attach the Layout of the Firefighting Equipment and Absorbent Material Locations)

**២.៣.៨ អំពីប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក** (Oil-Water Separation System)

ចង្អូរប្រមូលទឹកចោល (Collection Chanel): បណ្ដោយ (Length)________ ប្រវែងទទឹង (Width)________ ជម្រៅ (Depth)________

អាងញែក (Oil-water Separation Chamber: បណ្ដោយ (Length)________ ប្រវែងទទឹង (Width)________ ជម្រៅ (Depth)________

(សូមភ្ជាប់មកជាមួយនូវគំនូសបំព្រួញប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក: Please attach the layout of Oil-Water Separation System)

៣

២.៣.៥ អំពីការសាងសង់

កាលបរិច្ឆេទនៃការចាប់ផ្តើមសាងសង់ (Date of Construction Commencement): ____________

កាលបរិច្ឆេទនៃការសាងសង់ចប់ជាស្ថាពរ (Date of Completed Construction): ____________

កាលបរិច្ឆេទនៃការដាក់ដំណើរការ (Date of Operating): ____________

**៣- ព័ត៌មានអំពីបុគ្គលិកស្ថានីយ** (Information of Filling Station Employees)

ឈ្មោះអ្នកគ្រប់គ្រង ( Name of Manager): ____________ ភេទ (Sex) ______ ថ្ងៃខែឆ្នាំកំណើត (DoB) ____________

សញ្ជាតិ (Nationality): ____________ លេខទូរស័ព្ទ(Tel) ____________

(សូមភ្ជាប់មកនូវប្រវត្តិរូបសង្ខេប របស់អ្នកគ្រប់គ្រង Please Attach the Curriculum Vitae)

ចំនួនបុគ្គលិកសរុប( Total Number of Employees): ____________ នាក់

**៤- ព័ត៌មានពីទុនវិនិយោគ** (Information of the Investment)

តម្លៃប៉ាន់ស្មានវិនិយោគសរុប-គិតជារៀល (Estimated Total Investment Cost in Riel): ____________

**៥- ឯកសារភ្ជាប់មកជាមួយ** (Supporting Documents Attached) :

- ☐ រូបថតម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន ៤x៦ ចំនួន ៣សន្លឹក (3 Photos of Filling Station Owner or Company President 4x6)
- ☐ ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (Copy of ID or Passport) — ចំនួន ១ ច្បាប់ (1 copy)
- ☐ បង្កាន់ដៃកម្រៃសេវាសាធារណៈពិនិត្យពាក្យស្នើសុំ (Receipt of Public Service Fee for the Application) — ចំនួន ១ ច្បាប់ (1 copy)
- ☐ ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ពីស្ថាប័នមានសមត្ថកិច្ច (Copy of Construction Permits of Authorities — ចំនួន ១ ច្បាប់ (1 copy)
- ☐ ផែនទីបង្ហាញទីតាំងស្ថានីយដែលត្រូវបង្កើត (Location Map of Filling Station) — ចំនួន ១ ច្បាប់ (1 copy)
- ☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីជានីតិបុគ្គល) (Copy of Statute and Certificate of Business Registration, If Legal Entity) — ចំនួន ១ ច្បាប់ (1 copy)

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ដូចមានយោងខាងលើ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។ I/We, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃទី.......... ខែ.......... ឆ្នាំ.......... ព.ស..........

.......... ថ្ងៃទី.......... ខែ.......... ឆ្នាំ ..........

**ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ**

(Signature and Name of Applicant)

សម្រាប់មន្ត្រីទទួលពាក្យ៖..........

(Official Use Only)

## ឧបសម្ព័ន្ធទី ៣ នៃប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភាឆ្នាំ ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ

ទម្រង់លេខ ០០១ លអបជ

# ពាក្យសុំបន្តសុពលភាព លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈ

APPLICATION FORM FOR RENEWAL OF FILLING STATION OPERATION PERMIT

រូបថតអ្នកស្នើសុំ
Photo of applicant
4 x 6

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន។
The following information is to be filed by the owner of the filling station or president of the company.

**១- ស្ថានភាពទូទៅ**

☐ ស្ថានីយប្រេងឥន្ធនៈ (Fuel Station)

☐ ស្ថានីយឧស្ម័នឥន្ធនៈ (Gas Station)

☐ ស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ (Joint Fuel and Gas Station)

វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយដែលផុតសុពលភាព (Expired Certificate of Filling Station) លេខ៖ ____

កាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រដែលផុតសុពលភាព (Date of Issue) ____

កាលបរិច្ឆេទផុតសុពលភាពនៃវិញ្ញាបនបត្រដែលត្រូវផុតសុពលភាព (Expiry Date of the Expired Certificate) ____

**២- ព័ត៌មានអំពីបុគ្គលិកស្ថានីយ បើមានការផ្លាស់ប្តូរ** (Information of Filling Station Employees, If Changed)

ឈ្មោះអ្នកគ្រប់គ្រង ( Name of Manager): ____ ភេទ (Sex) ____ ថ្ងៃខែឆ្នាំកំណើត (DoB) ____

សញ្ជាតិ (Nationality): ____ លេខទូរស័ព្ទ(Tel.) ____

(សូមភ្ជាប់មកនូវប្រវត្តិរូបសង្ខេប របស់អ្នកគ្រប់គ្រង Please Attach the Curriculum Vitae)

ចំនួនបុគ្គលិកសរុប( Total Number of Employees): ____ នាក់

**៣- ឯកសារភ្ជាប់មកជាមួយ** (Supporting Documents Attached) :

☐ រូបថតម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន ៤x៦ ចំនួន ៣សន្លឹក (3 Photos of Filling Station Owner or Company President 4x6)

☐ ច្បាប់ចម្លងលិខិតអនុញ្ញាតដំណើរការស្ថានីយ ដែលផុតសុពលភាព ចំនួន ១ ច្បាប់ (1 copy)
(Copy of the Expired Permit of Filling Station Operation)

☐ បង្កាន់ដៃកម្រៃសេវាសាធារណៈពិនិត្យពាក្យស្នើសុំ ចំនួន ១ ច្បាប់ (1 copy)
*(Receipt of Public Service Fee for the Application)*

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ដូចមានរៀងខាងលើ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។ I/We, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃ....... ខែ....... ឆ្នាំ....... ព.ស.......

....... ថ្ងៃទី....... ខែ....... ឆ្នាំ .......

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
(Signature and Name of Applicant)

សម្រាប់មន្ត្រីទទួលពាក្យ៖ .......
(Official Use Only)

ទម្រង់លេខ ០០១ លកស

# ពាក្យសុំកែសម្រួលស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈ

APPLICATION FORM FOR RENOVATION OF FILLING STATION

រូបថតអ្នកស្នើសុំ
Photo of applicant
4 x 6

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន។
The following information is to be filed by the owner of the filling station or president of the company.

---

១- ស្ថានភាពទូទៅ

- ☐ ស្ថានីយប្រេងឥន្ធនៈ (Fuel Station)
- ☐ ស្ថានីយឧស្ម័នឥន្ធនៈ (Gas Station)
- ☐ ស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ (Joint Fuel and Gas Station)

លេខអត្តសញ្ញាណស្ថានីយ/Station ID No ៖ ____________

កាលបរិច្ឆេទនៃការចាប់ផ្តើមការកែសម្រួល (Planning Date of Renovation) ____________

កាលបរិច្ឆេទបញ្ចប់ការកែសម្រួល (Planning Date of completion) ____________

២- កម្មវត្ថុនៃការកែសម្រួល (Renovation Objects)

២.១ បរិក្ខារ (Facilities)

២.១.១ រៀបរាប់ពីបរិក្ខារដែលត្រូវកែសម្រួល (Describe About the Facilities Being Renovated)

____________
____________
____________
____________

២.១.២ មូលហេតុនៃការកែសម្រួល (Reasons)

____________
____________
____________
____________

២.១.៣ រៀបរាប់ពីបរិក្ខារថ្មីដែលត្រូវយកមកជំនួស (សូមភ្ជាប់ជាមួយនូវយថាប្រភេទ និងគំនូសប្លង់ដំឡើងនៃបរិក្ខារនីមួយៗ)៖
Describe about the New Facilities (Please Attach the Specification and the Installation Drawings)

____________
____________
____________
____________

២.២ ហេដ្ឋារចនាសម្ព័ន្ធ

២.២.១ រៀបរាប់ពីហេដ្ឋារចនាសម្ព័ន្ធដែលត្រូវកែសម្រួល (Describe about the Infrastructures Being Renovated)

____________
____________
____________

២.២.២ មូលហេតុនៃការកែសម្រួល (Reasons)

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

២.២.៣ រៀបរាប់ពីហេដ្ឋារចនាសម្ព័ន្ធថ្មី (សូមភ្ជាប់ជាមួយនូវគំនូសប្លង់ហេដ្ឋារចនាសម្ព័ន្ធនីមួយៗ)៖

Describe about the New Infrastructures (Please Attach the New Infrastructure Drawings)

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

៣- ឯកសារភ្ជាប់មកជាមួយ (Supporting Documents Attached) :

☐ បង្កាន់ដៃកម្រៃសេវាសាធារណៈពិនិត្យពាក្យស្នើសុំ ចំនួន ១ ច្បាប់ (1 copy)
(Receipt of Public Service Fee for the Application)

☐ គំនូសប្លង់បច្ចេកទេសរៀបចំសុវត្ថិភាពស្ថានីយថ្មី ក្នុងករណីមានការកែសម្រួលហេដ្ឋានរចនាសម្ព័ន្ធថ្មី ចំនួន ១ ច្បាប់ (1 copy)
(Updated Technical Drawing of Safety Preparation, in case of the Renovation of New Infrastructure)

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ដូចមានយោងខាងលើ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។ I/We, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃទី.................... ខែ.................. ឆ្នាំ.............. ព.ស.........................

............................. ថ្ងៃទី............ខែ.............. ឆ្នាំ ..............

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
(Signature and Name of Applicant)

សម្រាប់មន្ត្រីទទួលពាក្យ៖...............................................
(Official Use Only)

## ឧបសម្ព័ន្ធទី ៥ នៃប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភាឆ្នាំ ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ

ទម្រង់លេខ ០០១ ឈបម

# ពាក្យសុំប្តូរម្ចាស់ស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈ

APPLICATION FORM FOR CHANGE OF FILLING STATION OWNER

រូបថតអ្នកស្នើសុំ
Photo of applicant
4 x 6

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយម្ចាស់ស្ថានីយ ឬ ប្រធានក្រុមហ៊ុន។
The following information is to be filed by the owner of the filling station or president of the company

### ១- អំពីអ្នកស្នើសុំ (Applicant Information)

☐ រូបវន្តបុគ្គល (Natural Person) ☐នីតិបុគ្គល (Legal Entity)

ឈ្មោះអ្នកស្នើសុំ៖ ____ សញ្ជាតិ៖ ____ ភេទ៖ ☐ ប្រុស (Male)
Applicant's Name: ____ Nationality: ____ Sex: ☐ ស្រី (Female)

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number): ____ ថ្ងៃខែឆ្នាំកំណើត (DoB): ____

អាសយដ្ឋានអ្នកស្នើសុំ (Address of Applicant): ____

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____ អ៊ីម៉ែល (E-mail): ____

បំពេញព័ត៌មានខាងក្រោម ប្រសិនបើម្ចាស់អាជីវកម្មជានីតិបុគ្គល (Complete the following if the applicant is a legal entity) ៖

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ ប្រធានក្រុមហ៊ុន (Chairman/Managing Director/Director)
Position of Applicant in Company/Firm : ☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative)
(សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney)

នាមករណ៍ក្រុមហ៊ុន ៖ ____ លេខចុះបញ្ជីពាណិជ្ជកម្ម : ____
Firm/Company's Name : ____ Business Registration No ____

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ (Office's Address) : ____

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____ អ៊ីម៉ែល (E-mail) : ____

### ២- អំពីការផ្ទេរ ម្ចាស់ស្ថានីយ (Transfer of Filling Station Ownership)

#### ២.១- ប្រភេទស្ថានីយ (Type of Filling Station)

☐ ស្ថានីយប្រេងឥន្ធនៈ (Fuel Station)
☐ ស្ថានីយឧស្ម័នឥន្ធនៈ (Gas Station)
☐ ស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ (Joint Fuel and Gas Station)

#### ២.២ អំពីម្ចាស់ថ្មី

☐ រូបវន្តបុគ្គល (Natural Person) ☐នីតិបុគ្គល (Legal Entity)

ឈ្មោះម្ចាស់ថ្មី៖ ____ សញ្ជាតិ៖ ____ ភេទ៖ ☐ ប្រុស (Male)
Name of New Owner: ____ Nationality: ____ Sex: ☐ ស្រី (Female)

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number): ____ ថ្ងៃខែឆ្នាំកំណើត (DoB): ____

អាសយដ្ឋាន (Address): ____

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____ អ៊ីម៉ែល (E-mail): ____

បំពេញព័ត៌មានខាងក្រោម ប្រសិនបើម្ចាស់អាជីវកម្មថ្មីជានីតិបុគ្គល (Complete the following if the new owner is a legal entity) ៖

តួនាទី និងមុខងាររបស់ម្ចាស់ស្ថានីយថ្មីក្នុងក្រុមហ៊ុន ៖
Position of the New Owner in Company/Firm:

☐ ប្រធានក្រុមហ៊ុន (Chairman/Managing Director/Director)

☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative)
(សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney)

នាមករណ៍ក្រុមហ៊ុន ៖ ____________________ លេខចុះបញ្ជីពាណិជ្ជកម្ម : ____________________
Firm/Company's Name : ____________________ Business Registration No ____________________

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ (Office's Address) : ____________________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____________________ អ៊ីម៉ែល (E-mail) : ____________________

**២.៣ ព័ត៌មានអំពីបុគ្គលិកស្ថានីយ** (Information of Filling Station Employees)

ឈ្មោះអ្នកគ្រប់គ្រង ( Name of Manager): ____________________ ភេទ (Sex) ______ ថ្ងៃខែឆ្នាំកំណើត (DoB) ____________________

សញ្ជាតិ (Nationality): ____________________ លេខទូស័ព្ទ(Tel) ____________________

(សូមភ្ជាប់មកនូវប្រវត្តិរូបសង្ខេប របស់អ្នកគ្រប់គ្រង Please Attach the Curriculum Vitae)

ចំនួនបុគ្គលិកសរុប( Total Number of Employees): ____________ នាក់

**៣- ឯកសារភ្ជាប់មកជាមួយ** (Supporting Documents Attached) :

☐ រូបថតម្ចាស់ស្ថានីយថ្មី ឬ ប្រធានក្រុមហ៊ុនថ្មី ៤x៦ ចំនួន ៣សន្លឹក
(3 Photos of Filling Station New Owner or Company President 4x6)

☐ ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ម្ចាស់ថ្មី) — ចំនួន ១ ច្បាប់ (1 copy)
(Copy of New Owner's ID or Passport)

☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីជានីតិបុគ្គល) — ចំនួន ១ ច្បាប់ (1 copy)
(Copy of Statute and Certificate of Business Registration, If Legal Entity)

☐ ច្បាប់ថតចម្លងកិច្ចសន្យាលក់-ទិញស្ថានីយ ឬ លិខិតផ្ទេរស្ថានីយ រវាងម្ចាស់មុន និងម្ចាស់ថ្មី — ចំនួន ១ ច្បាប់ (1 copy)
(Copy of Filling Station Sale-Purchase Contract or Transferred Letter)

☐ បង្កាន់ដៃកម្រៃសេវាសាធារណៈពិនិត្យពាក្យស្នើសុំ — ចំនួន ១ ច្បាប់ (1 copy)
(Receipt of Public Service Fee for the Application)

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ដូចមានយោងខាងលើ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។ I/We, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃទី.............. ខែ.............. ឆ្នាំ.......... ព.ស..............
.................... ថ្ងៃទី.......... ខែ.............. ឆ្នាំ..........
ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
(Signature and Name of Applicant)

សម្រាប់មន្ត្រីទទួលពាក្យ៖..................................
(Official Use Only)